# ឧបករណ៍តន្ត្រីខ្មែរ៖ ក្រពើ

ខ្មែរយើងប្រើឈ្មោះផ្សេងៗគ្នា សំដៅទៅលើឧបករណ៍តន្ត្រីខ្មែរ «ក្រពើ»។[១] គេឃើញមានប្រភេទឧបករណ៍តន្ត្រី ក្រពើ នេះនៅក្នុងតំបន់អាស៊ី ដូចជាប្រទេសហ្វីលីពីន ម៉ាឡេស៊ី ឥណ្ឌូណេស៊ី មីយ៉ាន់ម៉ា ថៃឡង់ដ៍ ឡាវ និងកម្ពុជា។ នៅក្នុងបណ្ដាប្រទេសទាំងនេះ គេប្រើឈ្មោះនៅក្នុងចំណាត់ថ្នាក់តន្ត្រី (Organology) ថា «លូត» ឬ «ហ្ស៊ីធើ» (lute or zither: boat lute, boat zither, board zither, box zither, or floor zither)។

នៅក្នុងចំណាត់ថ្នាក់តន្ត្រី «លូត» (lute) ជាប្រភេទឧបករណ៍ន្ត្រី «ចាប៉ី» ដែលគេច្រើនព្យួរនឹងក ហើយដេញឬកេះ។ ឯ «ហ្ស៊ីធើ» (zither) គេដាក់នៅលើផ្ទៃរាបស្មើមួយ ដែលអ្នកលេងអង្គុយនៅពីក្រោយឧបករណ៍ហើយដេញឬកេះដែរ។ ចំណែកឯពាក្យដែលគេភ្ជាប់ជាមួយពាក្យ «លូត ឬ ហ្ស៊ីធើ» មួយម៉ាត់ទៀតគឺ «ទូក (boat), ប្រអប់ (board/box), និងក្តារឬផ្ទៃក្រាល (floor)» គឺសំដៅទៅលើរូបរាងឬសណ្ឋានឧបករណ៍ដែលមានរាងឬសណ្ឋានដូចទូកឬប្រអប់ និងដាក់នៅលើក្តារឬផ្ទៃក្រាលដើម្បីនឹងសម្តែង។ តាមការពិត លូតនិងហ្ស៊ីធើ ទោះបីវាជាគ្រឿងខ្សែនិងដេញឬកេះដូចគ្នាមែនពិត តែវាជាប្រភេទឧបករណ៍តន្ត្រីពីរផ្សេងគ្នា។ ឯកសារមួយចំនួនបានអះអាងថា ប្រភេទឧបករណ៍តន្ត្រីហ្ស៊ីធើ មានការអភិវឌ្ឍនិងក្លាយមកពីប្រភេទឧបករណ៍តន្ត្រីលូត។ មានន័យថា ឧបករណ៍ក្រពើ មានការអភិវឌ្ឍនិងក្លាយមកពីឧបករណ៍ចាប៉ី។ លោក ប៉ាទ្រិក កែរសាឡេ (Patrick Kersalé) យល់ថាអំណះអំណាងនេះមិនត្រឹមត្រូវទេ ទោះបីប្រភេទឧបករណ៍លូតនិងហ្ស៊ីធើស្ថិតនៅក្នុងចំណាត់ថ្នាក់តន្ត្រីជាគ្រឿងខ្សែដូចគ្នាក៏ដោយ។[២] លើសពីនេះទៅទៀត លោកក៏បានផ្តល់ជាព័ត៌មានថា ឧបករណ៍តន្ត្រីក្រពើខ្មែរ (ដែលមានរូបរាងជាសត្វក្រពើ) ចុងក្រោយ គឺបាន

[១] *Musique Khmère* 1969: 56-57; Sam 2002: 63; «ត:ខេ» (កែវ ដូរីវណ្ណ ជាដើម ១៩៩៤: ១៩(;» «តាខេ(កែវ ណារុំ ២០១១: ៤៣(

[២] Kersalé (2021)

អត្ថបទដោយ៖ បណ្ឌិត សំ សំអាង

សម្តែងដោយតន្ត្រីករខ្មែររស់នៅក្នុងខេត្តសុរិន្ទ (ប្រទេសថៃឡង់ដ៍) ដែលបានទទួលមរណភាពកាលពីអំឡុងដើមទសវត្ស២០១០ទៅហើយ។[៣]

ចំណុចសំខាន់មួយដែលគួរធ្វើការកត់សម្គាល់គឺ នៅក្នុងឆ្នាំ១៩៣០ ព្រះរាជាថៃ ព្រះបាទ ប្រជាធិផុក (រាមាទី៧) នៅឱកាសដែលព្រះអង្គបានយាងទៅធ្វើព្រះរាជទស្សនកិច្ចនៅប្រទេសកម្ពុជា ព្រះអង្គបានទទួលព្រះរាជទានពីព្រះបាទសម្តេចព្រះស៊ីសុវត្ថិ មុនីវង្ស នូវឧបករណ៍តន្ត្រីខ្មែរដ៏ប្រណិតមួយចំនួន ដែលនៅក្នុងនោះមានឧបករណ៍ក្រពើមួយផងដែរ។ ឧបករណ៍តន្ត្រីក្រពើខ្មែរនេះ បានត្រូវថៃថែរក្សាដោយយកចិត្តទុកដាក់ ដែលសព្វថ្ងៃនេះ គេដាក់តាំងនៅសារមន្ទីរជាតិថៃនាទីក្រុងបាងកក។[៤]

ឯរូបរាងឬសណ្ឋានដូចទូក ជាតិពន្ធុតន្ត្រីវិទូ (ethnomusicologist) ដូចជាលោកបណ្ឌិតសាស្ត្រាចារ្យ រ៉ាម៉ុន សាន់តូស (Ramon P. Santos) បានមានប្រសាសន៍ថាមិនត្រឹមត្រូវទេ ដោយរូបរាងឬសណ្ឋានដែលថាដូចទូកនោះ តាមការពិតវាដូចជាក្រពើទេតើ។ ដូច្នេះហើយបានជានៅក្នុងន័យនេះ យើងហៅវាថា «ក្រពើ»។[៥]

នៅប្រទេសមីយ៉ានម៉ា ឧបករណ៍ស្រដៀងគ្នាហៅ មីហ្គីយ៉ង (Mi-gyaung) មានរូបរាងនិងសណ្ឋានជាសត្វក្រពើដោយគេមានជំនឿថាគេខ្លាចសត្វល្មូន (reptile) ដែលជានិម្មិតរូបនៃសេចក្តីស្លាប់។[៦] អំពីឧបករណ៍មីហ្គីយ៉ង លោក រ៉ូប៊ើត ហ្គាហ្វីយ៉ាស (Robert Garfias) បានមានប្រសាសន៍ថា ឧបករណ៍នេះ គឺគេនៅឃើញមានប្រើប្រាស់នៅក្នុងវង់តន្ត្រីជនជាតិភាគតិចមនក្នុងតំបន់ក្បែរៗទីក្រុង មូឡឺម៉េន (Moulemein)។ យ៉ាងណាមិញ តន្ត្រីករបុរាណភូមានៅប្រើប្រាស់ឧបករណ៍នេះរហូតដល់ទសវត្ស១៩២០និង១៩៣០។[៧]

---

[៣] Kersalé (2021)

[៤] Kersalé (2021)

[៥] 2017: 22

[៦] Kersalé (2021)

[៧] 1975: 4

ដោយឡែក ពាក់ព័ន្ធនឹងឧបករណ៍តន្ត្រី ចាខេ ថៃ លោក ធែរី មីលើ (Terry Miller) បានមានប្រសាសន៍យ៉ាងក្បោះក្បាយថា ឧបករណ៍ចាខេថៃខ្សែបី ដែលគេបានរៀបរាប់ឡើងមុនដំបូងបង្អស់ ប្រាកដជាចេញមកពីប្រភពឧបករណ៍តន្ត្រី មីហ្គីយ៉ង មនឬភូមា។[៨]

ក្រពើ តាខេ ឬត:ខេខ្មែរ (ក្រពើឯក និង ក្រពើធុង) មានរូបរាងឬសណ្ឋានជាសត្វក្រពើ។ ឧបករណ៍ក្រពើខ្លះ មានឆ្លាក់ធ្វើជាក្រពើហារមាត់និងមានធ្មេញផង។ គេដាក់ឧបករណ៍ក្រពើនៅលើក្តារឬផ្ទៃក្រាល អ្នកសម្តែងអង្គុយនៅពីក្រោយឧបករណ៍ ដេញឬកេះដោយប្រើក្រចកធ្វើពីភ្លុក ឆ្អឹង ស្នែង ឬឈើខ្លឹម។ ឧបករណ៍ក្រពើ មានជើងទ្រប្រាំឱ្យខ្ពស់ផុតពីក្តារ ឬផ្ទៃក្រាល។ ឧបករណ៍ក្រពើខ្មែរ មានខ្សែបីធ្វើពីស្ពាន់និងនីឡុង។ ឧបករណ៍ក្រពើឯកខ្មែរ មានខ្សែបន្ទរសំឡេងក្រោម សូរប្រមាណ A (បស្ចឹមប្រទេស), ខ្សែគរសំឡេងកណ្តាល សូរ D (បស្ចឹមប្រទេស), និងខ្សែឯកសំឡេងខ្ពស់ សូរ G (បស្ចឹមប្រទេស)។ ខ្នងរបស់ឧបករណ៍ក្រពើខ្មែរមាន១២ ធ្វើពីភ្លុក ឆ្អឹង ឬស្សី ឬឈើខ្លឹម។

សរុបសេចក្តីមក សំណួរសួរថា ហេតុអ្វីបានជាមានការវិវត្តនិងការអភិវឌ្ឍពីលូតទៅហ្សុឺឌើ? ចម្លើយជាយោបល់ខ្លះពោលថា ដោយសារតម្រូវការឱ្យមានសូរខ្លាំងលើសពីលូត ទើបហ្សុឺឌើ មានការអភិវឌ្ឍរូបរាងនិងប្រអប់សូរធំជាងលូត។

ម្យ៉ាងទៀត កត្តាពេលវេលានិងការយកចិត្តទុកដាក់ ការយល់ដឹង ស្រឡាញ់ជំនាញនិងអាជីព ព្រមទាំងស្មារតីគោរព អភិរក្ស ថែរក្សា និងអភិវឌ្ឍន៍វប្បធម៌ខ្មែរ ពិតជាមានឥទ្ធិពលទៅលើបាត់បង់ឧបករណ៍តន្ត្រីក្រពើខ្មែរ ក៏ដូចជាឧបករណ៍តន្ត្រីក្រពើរបស់ជាតិសាសន៍ឯទៀតនៅលើពិភពលោកដែរ។

---

[៨] Miller 1984: 36; Turpin 1771: 125



ឧបករណ៍តន្ត្រីខ្មែរ ក្រពី, ខេត្តសារិន (**ប្រភព៖** Photo: Michel Antelme, https://www.soundsofangkor.org/english/traditional-music/zither-krapeu/)



ឧបករណ៍តន្ត្រីខ្មែរ «តាខេ»

អត្ថបទដោយៈ បណ្ឌិត សំ សំអាង



ឧបករណ៍តន្ត្រីថៃ «ក្រពី»

(ប្រភព៖ https://mimo-international.com/MIMO/detailstatic.aspx?RSC_BASE=IFD&RSC_DOCID=MINIM_UK_43937&TITLE=/chakhe)



ឧបករណ៍តន្ត្រីភូមា «ក្រពី» (ប្រភព៖ SAS)

# ឯកសារពិគ្រោះ

*កែវ ដូរីវណ្ណ, ជាដើម. (១៩៩៤). ឧបករណ៍តន្ត្រីកម្ពុជា. ភ្នំពេញ: យូណេស្កូ។*

*កែវ ណារុំ. (២០១១). តន្ត្រីនៅប្រទេសខ្មែរ. ភ្នំពេញ: គ្រឹះស្ថានបោះពុម្ពផ្សាយនគរវត្ត។*

Brandeis, Hans. (2017). “A Boat Lute Odyssey.” *Agung*, 20(6), 23-37.

Douglas, Gavin, Reviewer. (2010). *The Journal of American Folklore*, *123*(487), 113-116.

Garfias, Robert. (1975). “A Musical Visit to Burma,” *The World of Music*, *17*(1), 3-13.

Kersalé, Patrick. (2021). *Zither – Krapeu*.In SoundsofAngkor.org

Miller, Terry. (1984). “Reconstructing Siamese Musical History from Historical Sources: 1548-1932,” Asian Music, *15*(2), 32-42.

*Musique Khmère*. (1969). Phnom Penh: Imprimerie Sangkum Réastr Niyum.

Sam, Sam-Ang. (2002). *Musical Instruments of Cambodia*. Osaka: National Museum of Ethnology.

Santos, Ramon P. (2017). “Musical Instruments as Emblems in the Socio-Cultural Communities in the Philippines,” *Agung*, *20*(6), 1-22.

Turpin, François Henri. (1771). *Histoire Civile et Naturalle du Royaume de Siam jusqu’en 1770*, 2 vols. Paris: Costard.

AMS
អរិយធម៌ខ្មែរ
KHMER CIVILIZATION

*អត្ថបទដោយ៖ បណ្ឌិត សំ សំអាង*